**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។



www.pheakdeylaw.com

**មាត្រា ២ .-**

អនុក្រឹត្យនេះ មានគោលដៅដូចខាងក្រោម៖

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- រៀបចំមុខងារ និងភារកិច្ចរបស់អង្គភាពនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងវិស័យសាធារណការ និងដឹកជញ្ជូន។

**មាត្រា ៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពចំណុះ ក្រសួងសាធារណការ និងដឹកជញ្ជូន រួមមានទាំងអង្គភាពថ្នាក់កណ្តាល អង្គភាពថ្នាក់មូលដ្ឋាន និងសហគ្រាសសាធារណៈ ព្រមទាំងគ្រប់ដណ្តប់លើវិស័យសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ៤ .-**

ក្រសួងសាធារណការ និងដឹកជញ្ជូន បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងបេសកកម្មដឹកនាំ គ្រប់គ្រងលើវិស័យសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើងជីវភាពរស់នៅរបស់ប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី និងសមធម៌សង្គម។

បេសកកម្មនេះធ្វើឡើងតាមរយៈការរៀបចំ និងការអនុវត្តន៍ឱ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យសាធារណការ និងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៥ .-**

ក្រសួងសាធារណការ និងដឹកជញ្ជូនមានមុខងារ និងភារកិច្ចដូចតទៅ៖

- រៀបចំ អនុវត្ត និងតាមដានការអនុវត្តន៍គោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់អភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន
- រៀបចំផែនការមេ បណ្តាញដឹកជញ្ជូន តាមផ្លូវគោក ផ្លូវដែក ផ្លូវទឹក ផ្លូវសមុទ្រ កំពង់ផែ ឬតាមបណ្តាញផ្សេងៗទៀតដែលអនុញ្ញាតដោយរាជរដ្ឋាភិបាល
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន សិក្សាស្រាវជ្រាវគម្រោងប្លង់ និងវាយតម្លៃលើការងារសាងសង់ អភិវឌ្ឍ ជួសជុល និងថែទាំផ្លូវថ្នល់ ស្ពាន កំពង់ចម្លង ផ្លូវដែក ផ្លូវទន្លេ ផ្លូវសមុទ្រ កំពង់ផែ កស្តុភារកម្ម និងការងារផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យសាធារណការ និងដឹកជញ្ជូន
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការងារអាជីវកម្មដឹកជញ្ជូនតាមផ្លូវគោក ផ្លូវទឹក ផ្លូវសមុទ្រ ផ្លូវដែក កស្តុភារកម្ម និងការងារផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យសាធារណការ និងដឹកជញ្ជូន
- គ្រប់គ្រង វាយតម្លៃ ទទួលស្គាល់ និងផ្តល់វិញ្ញាបនបត្រអនុញ្ញាតការធ្វើអាជីវកម្មសាងសង់សំណង់ទាំងឡាយដែលបម្រើដល់វិស័យសាធារណការ និងដឹកជញ្ជូន
- រៀបចំកសាងសេចក្តីព្រាងច្បាប់ គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងវិស័យសាធារណការ និងដឹកជញ្ជូន ព្រមទាំងតាមដាន ត្រួតពិនិត្យការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្តទាំងអស់នោះសម្រាប់វិស័យសាធារណការ និងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំ គ្រប់គ្រង តាមដាន និងត្រួតពិនិត្យការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ រួមទាំងមាត់វិធានការអនុវត្តយ៉ាងម៉ឺងម៉ាត់ ដើម្បីការពារផ្លូវថ្នល់ ស្ពាន ឬហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្សេងទៀត
- សិក្សា ស្រាវជ្រាវ និងពិសោធន៍របធាតុសម្រាប់ការសាងសង់សំណង់ផ្លូវថ្នល់ ស្ពាន និងវាយតម្លៃ ទទួលស្គាល់គុណភាព



www.pheakdeylaw.com

សំណង់ផ្លូវថ្នល់ ស្ពាន រួមទាំងសំណង់សិល្បការ្យផ្លូវថ្នល់ ផ្លូវដែក និងផែ

- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយបទប្បញ្ញត្តិបច្ចេកទេស ឬស្តង់ដាបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗ ដើម្បីធានានូវគុណភាពសំណង់ហេដ្ឋារចនាសម្ព័ន្ធសាធារណការ សំណង់ផ្លូវដែក និងសំណង់កំពង់ផែ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំ និងចូលរួមរៀបចំ អនុវត្តគោលនយោបាយយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ លើវិស័យសាធារណការ និងដឹកជញ្ជូន និងកិច្ចការធ្វើសមាហរណកម្មព្រះរាជាណាចក្រកម្ពុជាចូលក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ និងសកលលោក
- ជំរុញ និងលើកទឹកចិត្តដល់ផ្នែកឯកជន ចូលរួមក្នុងការអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា
- អភិវឌ្ឍធនធានមនុស្ស ដោយការលើកទឹកចិត្តដល់ការសិក្សា ស្រាវជ្រាវបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យាថ្មីៗ ដល់ការអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន
- ជាអាណាព្យាបាលបច្ចេកទេសលើសហគ្រាសសាធារណៈដូចជា កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ ភ្នាក់ងារកម្ពុជានាវាចរ (កាំសាប) មន្ទីរពិសោធន៍សំណង់ និងសាធារណការ និងអង្គភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យសាធារណការ និងដឹកជញ្ជូន
- ធ្វើអធិការកិច្ច និងសវនកម្មបច្ចេកទេស លើវិស័យសាធារណការ និងដឹកជញ្ជូន
- ធ្វើអធិការកិច្ច និងសវនកម្មផ្ទៃក្នុងលើការគ្រប់គ្រងវិស័យសាធារណការ និងដឹកជញ្ជូន។

**មាត្រា ៦ .-**

ក្រសួងសាធារណការ និងដឹកជញ្ជូន មានរចនាសម្ព័ន្ធដូចតទៅ៖

**ក- អង្គភាពថ្នាក់កណ្តាល**

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ
- អគ្គនាយកដ្ឋានបច្ចេកទេស
- អគ្គនាយកដ្ឋានសាធារណការ
- អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
- អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ
- អគ្គនាយកដ្ឋានភស្តុភារកម្ម
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- នាយកដ្ឋានផ្លូវដែក
- នាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ
- អង្គភាពលទ្ធកម្ម។

**ខ- អង្គភាពថ្នាក់មូលដ្ឋាន**

- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត
- ការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក ខណ្ឌ។

**គ- សហគ្រាសសាធារណៈ**

- កំពង់ផែស្វយ័តក្រុងព្រះសីហនុ ៤៤



www.pheakdeylaw.com

- កំពង់ផែស្វយ័តភ្នំពេញ
- ភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)
- មន្ទីរពិសោធន៍សំណង់ និងសាធារណការ។

**មាត្រា ៧ .-**

អគ្គនាយកដ្ឋាន ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន ជាជំនួយការ ព្រមទាំងមានអធិការ និងអធិការរងមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

វិទ្យាស្ថានជាតិ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន ជាជំនួយការ មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន ជាជំនួយការ។

អង្គភាពលទ្ធកម្ម ដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន មានឋានៈស្មើប្រធានការិយាល័យនៅអង្គភាពថ្នាក់កណ្តាល ជាជំនួយការ។

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន ជាជំនួយការ។

ការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក ខណ្ឌ ចំណុះឱ្យមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី-ខេត្ត ដឹកនាំដោយប្រធានការិយាល័យមួយរូប និងអមដោយអនុប្រធានការិយាល័យមួយចំនួនអនុលោមតាមបទប្បញ្ញត្តិជាធរមាន ជាជំនួយការ។

អង្គការលេខរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា ៨ .-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពថ្នាក់កណ្តាល និងអង្គភាពថ្នាក់មូលដ្ឋានត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

## ជំពូកទី ៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៩ .-**

ខុទ្ទកាល័យក្រសួងសាធារណការ និងដឹកជញ្ជូន ទទួលបន្ទុកបេសកកម្មទាំងឡាយ ដូចបានកំណត់តាមអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងលេខាធិការដ្ឋាន។

## ជំពូកទី ៤
## អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា ១០ .-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលកិច្ចការរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ផ្គត់ផ្គង់ សម្ភារៈបរិក្ខា ទ្រព្យសម្បត្តិរដ្ឋ ឯកសារ និងបូកសរុប នីតិកម្ម និងសហប្រតិបត្តិការអន្តរជាតិ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះចំនួន៥ ដូចខាងក្រោម៖

១- នាយកដ្ឋានរដ្ឋបាល



www.pheakdeylaw.com

២- នាយកដ្ឋានបុគ្គលិក
៣- នាយកដ្ឋានហិរញ្ញវត្ថុ
៤- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
៥- នាយកដ្ឋាននីតិកម្ម

**មាត្រា ១១ .-**

នាយកដ្ឋានរដ្ឋបាល មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងត្រា និងឯកសារចេញ-ចូលក្រសួង
- រៀបចំសន្តិសុខ សណ្តាប់ធ្នាប់របស់ក្រសួង
- សម្របសម្រួលការងារពិធីការ បដិសណ្ឋារកិច្ច សិក្ខាសាលា សន្និបាតបូកសរុបលទ្ធផលការងារ និងកិច្ចការពាក់ព័ន្ធនឹងការរៀបចំពិធីបុណ្យ ពិធីផ្សេងៗរបស់ក្រសួង រួមទាំងការគ្រប់គ្រង និងចាត់ចែងការងារសន្តិសុខ និងសណ្តាប់ធ្នាប់ក្រសួង
- គ្រប់គ្រងបណ្ណាល័យក្រសួង ដោយប្រមូលចងក្រង រក្សាទុក និងថែរក្សាឯកសារនានា ឱ្យស្របតាមកាលប្បវត្តិ ព្រមទាំងតម្កល់ទុកឯកសារតាមប្រព័ន្ធព័ត៌មានវិទ្យាទាំងផ្នែកទន់ និងផ្នែករឹងរបស់ក្រសួង ដើម្បីបង្កភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ និងការប្រើប្រាស់តាមតម្រូវការចាំបាច់
- ពិនិត្យ ផ្តល់យោបល់ និងស្នើសុំគោលការណ៍កម្ទេចចោលឯកសារហួសសុពលភាពឱ្យស្របតាមច្បាប់ និងលិខិតគតិយុត្តជាធរមាន
- តាមដាន និងជំរុញអនុវត្តការងារបូកសរុបរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារសម្រេចបានរបស់ក្រសួង ព្រមទាំងលើកទិសដៅអនុវត្តបន្ត
- សម្របសម្រួលផ្នែករដ្ឋបាល និងកិច្ចការទូទៅរបស់ក្រសួងនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ព្រមទាំងអង្គភាពនានាក្រោមឱវាទក្រសួង
- គ្រប់គ្រង និងសម្របសម្រួលនូវរាល់សកម្មភាពទាំងឡាយពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលរបស់ក្រសួងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ រួមទាំងសហគ្រាសសាធារណៈ ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ១២ .-**

នាយកដ្ឋានបុគ្គលិក មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង និងអភិវឌ្ឍនធនធានមនុស្សរបស់ក្រសួងអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សម្របសម្រួល ត្រួតពិនិត្យ ផ្តល់យោបល់ និងជំរុញការរៀបចំការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់ក្រសួង
- តាមដាន ពិនិត្យ និងផ្តល់យោបល់លើការគ្រប់គ្រងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការ
- រៀបចំបែបបទ ជ្រើសរើស តែងតាំង ដំឡើងថ្នាក់ ដំឡើងឋានន្តរស័ក្តិ ចូលនិវត្តន៍ ផ្លាស់ប្តូរ លើកសរសើរ លើកទឹកចិត្ត ទណ្ឌកម្ម និងលុបឈ្មោះបុគ្គលិក
- រៀបចំសំណុំលិខិត ស្ថិតិបុគ្គលិក និងគ្រប់គ្រងព័ត៌មានបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា
- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្ស និងការងារវិភាគមុខងារ
- វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក
- រៀបចំបៀវត្ស ប្រាក់កម្រៃ និងរបបឧបត្ថម្ភផ្សេងៗ



www.pheakdeylaw.com

- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ១៣ .-**

នាយកដ្ឋានហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ប្រតិបត្តិការគណនេយ្យ ហិរញ្ញវត្ថុ
- សម្របសម្រួល ពិនិត្យ ផ្តល់យោបល់ និងជំរុញលើការងាររៀបចំ និងការគ្រប់គ្រងថវិកា គណនេយ្យ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៃអង្គភាពចំណុះ និងក្រោមអាណាព្យាបាលរបស់ក្រសួង
- ពិនិត្យ ផ្តល់យោបល់ តាមដាន និងជំរុញលើការរៀបចំគម្រោងថវិកាក្រសួង
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកាសម្រាប់បម្រើឱ្យរាល់ការចំណាយរបស់ក្រសួង រួមទាំងការចំណាយអនុវត្តគម្រោងសាងសង់ ជួសជុល និងថែទាំដែលបម្រើឱ្យវិស័យសាធារណការ និងដឹកជញ្ជូន
- ពិនិត្យ ផ្តល់យោបល់ តាមដាន និងជំរុញឱ្យមានការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដូចជា ចលនទ្រព្យ អចលនទ្រព្យ សន្និធិ សម្ភារៈ ការធ្វើបញ្ជីសារពើភ័ណ្ឌ និងកម្មវិធីចំណាយរបស់ក្រសួង
- រៀបចំបែងចែកលាភការ សម្ភារៈបរិក្ខារ ប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ឱ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព
- រៀបចំផែនការហិរញ្ញវត្ថុរយៈពេលមធ្យមសម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន
- ប្រមូលតម្រូវការថវិការបស់អង្គភាពរដ្ឋបាលកណ្តាល និងបូកសរុបរៀបចំគម្រោងចំណូល និងចំណាយថវិកាប្រចាំឆ្នាំ
- រៀបចំប្រព័ន្ធគ្រប់គ្រងប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុសម្រាប់អង្គភាពរដ្ឋបាលកណ្តាល និងរាជធានី ខេត្ត
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមការកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ១៤ .-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងកិច្ចសហប្រតិបត្តិការអន្តរជាតិអនុតំបន់ តំបន់ និងអន្តរជាតិ
- ធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានា សហគមន៍ និងដៃគូអភិវឌ្ឍន៍ ដើម្បីរកថវិកា សម្រាប់បណ្តុះបណ្តាលធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន
- សម្របសម្រួល និងធ្វើទំនាក់ទំនងការងារសហប្រតិបត្តិការអន្តរជាតិ ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើវិស័យសាធារណការ និងដឹកជញ្ជូន
- ពង្រឹងកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលទំនាក់ទំនងជាមួយអង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល របស់បណ្តាប្រទេសនានា ដែលផ្តល់ការគាំទ្រលើវិស័យសាធារណការ និងដឹកជញ្ជូនតាមគោលការណ៍របស់រាជរដ្ឋាភិបាល
- រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការអន្តរជាតិជូនថ្នាក់ដឹកនាំក្រសួងសម្រាប់ចរចាចុះហត្ថលេខាលើកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀងផ្សេងៗ
- សហការសម្របសម្រួលរាល់សកម្មភាពគ្រប់អង្គភាព ដែលដំណើរការក្រោមឥណទានរបស់ជំនួយទ្វេភាគី ពហុភាគី ជាមួយរាជរដ្ឋាភិបាល ឬជាមួយស្ថាប័ននានា
- សម្របសម្រួល និងគ្រប់គ្រងទិន្នន័យព័ត៌មាន ជំនួយ និងកម្ចីបរទេស ដែលពាក់ព័ន្ធជាមួយវិស័យសាធារណការ និងដឹកជញ្ជូន
- តាមដាន និងវាយតម្លៃការអនុវត្តខ្លឹមសារសហប្រតិបត្តិការអន្តរជាតិ ពាក់ព័ន្ធជាមួយវិស័យសាធារណការ និងដឹកជញ្ជូនដែលមានចែងក្នុងកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខារួច



www.pheakdeylaw.com

- បូកសរុបការងារសហប្រតិបត្តិការអន្តរជាតិជាមួយស្ថាប័ននានាតាមរបបកំណត់
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមការកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ១៥ .-**

នាយកដ្ឋាននីតិកម្ម មានភារកិច្ចដូចតទៅ៖

- ជាសេនាធិការរបស់ក្រសួងលើការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានារបស់កម្ពុជា ដែលទាក់ទងនឹងកិច្ចព្រមព្រៀង សន្ធិសញ្ញា អនុស្សរណៈផ្សេងៗ ពាក់ព័ន្ធនឹងវិស័យសាធារណការ និងដឹកជញ្ជូន
- សិក្សាស្រាវជ្រាវ និងរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងឯកសារផ្សេងៗរបស់ក្រសួង
- ជាសេនាធិការរបស់ក្រសួងលើការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- សម្របសម្រួល ពិនិត្យ ផ្តល់យោបល់ និងជំរុញការរៀបចំការងារពាក់ព័ន្ធនឹងកិច្ចការនីតិកម្ម
- ចូលរួមរៀបចំ ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន អង្គភាពនានា ព្រមទាំងសហគ្រាសសាធារណៈនានាចំណុះក្រសួងសាធារណការ និងដឹកជញ្ជូន
- ចូលរួមពិនិត្យ និងផ្តល់យោបល់ និងសហការរៀបចំ ឬកសាងច្បាប់លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យសាធារណការ និងដឹកជញ្ជូន
- ជំរុញការងារសិក្សាស្រាវជ្រាវ ចងក្រង និងរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងធ្វើការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមការកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ជំពូកទី ៥

## អគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ

**មាត្រា ១៦ .-**

អគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ មានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការរៀបចំផែនការ ប្រព័ន្ធព័ត៌មាន គោលនយោបាយ តាមដាន និងវាយតម្លៃលើវិស័យសាធារណការ និងដឹកជញ្ជូន។

អគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ មាននាយកដ្ឋានចំណុះចំនួន៤ ដូចខាងក្រោម៖

១- នាយកដ្ឋានផែនការ

២- នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រង

៣- នាយកដ្ឋានគោលនយោបាយ

៤- នាយកដ្ឋានពិនិត្យ តាមដាន និងវាយតម្លៃ។

**មាត្រា ១៧ .-**

នាយកដ្ឋានផែនការ មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន
- រៀបចំស្ថិតិ និងសម្របសម្រួលផែនការអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន
- ធ្វើបច្ចុប្បន្នកម្មផែនការនូវរាល់សកម្មភាពទាំងឡាយពាក់ព័ន្ធនឹងកិច្ចការសាធារណការ និងដឹកជញ្ជូន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ



www.pheakdeylaw.com

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគសាធារណៈ និងឯកជននៅក្នុងវិស័យសាធារណការ និងដឹកជញ្ជូន
- សម្របសម្រួល និងកៀងគរធនធានហិរញ្ញប្បទានសម្រាប់អភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន
- តាមដាន និងជំរុញការងាររៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍរយៈពេលវែង មធ្យម និងខ្លី យុទ្ធសាស្ត្រផែនការអភិវឌ្ឍជាតិ ផែនការ៥ឆ្នាំ ផែនការ៣ឆ្នាំរំកិល កម្មវិធីវិនិយោគសាធារណៈ និងឯកជន ផែនការថ្នាំលើការងារជួសជុលថែទាំផ្លូវថ្នល់ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងផែនការកស្តុភារកម្ម
- ចូលរួមសហការលើការរៀបចំយុទ្ធសាស្ត្រ ការសិក្សាផែនការមេ និងផែនការអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន កស្តុភារកម្ម ឬការរៀបចំយុទ្ធសាស្ត្រ ផែនការមេ និងផែនការអភិវឌ្ឍតាមអនុវិស័យ ផ្លូវថ្នល់ ការដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក នាវាសមុទ្រ កំពង់ផែ និងកស្តុភារកម្ម
- ចូលរួមសហការ និងពិនិត្យផ្តល់យោបល់លើការរៀបចំផែនការថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការងារសាធារណការ និងដឹកជញ្ជូន
- ពិនិត្យផ្តល់យោបល់ និងចូលរួមក្នុងសកម្មភាពវាយតម្លៃ និងដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច សង្គមដោយសារគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណការ និងដឹកជញ្ជូន
- សិក្សា ស្រាវជ្រាវ និងតាមដានការប្រែប្រួលនិន្នាការក្នុងតំបន់ និងពិភពលោក ដើម្បីកសាងគោលនយោបាយវិស័យសាធារណការ និងដឹកជញ្ជូន
- ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តន៍គោលនយោបាយ ផែនការ កម្មវិធី គម្រោងអភិវឌ្ឍន៍វិស័យសាធារណការ និងដឹកជញ្ជូន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមការកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ១៨ .-**

នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រង មានភារកិច្ចដូចតទៅ៖

- សហការជាមួយក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍពាក់ព័ន្ធ ដើម្បីអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងវិស័យសាធារណការ និងដឹកជញ្ជូន
- ធ្វើបច្ចុប្បន្នកម្មស្ថិតិវិស័យសាធារណការ និងដឹកជញ្ជូន វិភាគ និងផលិតស្ថិតិ សូចនាករ និងបោះពុម្ពផ្សព្វផ្សាយជាសាធារណៈ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ១៩ .-**

នាយកដ្ឋានគោលនយោបាយ មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយពាក់ព័ន្ធវិស័យសាធារណការ និងដឹកជញ្ជូន
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍក្នុងការធ្វើបច្ចុប្បន្នកម្មគោលនយោបាយ
- សិក្សា ស្រាវជ្រាវ និងតាមដានការវិវឌ្ឍក្នុងតំបន់ និងពិភពលោក ដើម្បីកសាងគោលនយោបាយសាធារណការ និងដឹកជញ្ជូន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។ ៚



www.pheakdeylaw.com

**មាត្រា ២០ .-**

នាយកដ្ឋានពិនិត្យ តាមដាន និងវាយតម្លៃ មានភារកិច្ចដូចតទៅ៖

- រៀបចំប្រព័ន្ធវាយតម្លៃការអនុវត្តគោលនយោបាយ និងផលប៉ះពាល់សេដ្ឋកិច្ចវិស័យសាធារណការ និងដឹកជញ្ជូន
- អភិវឌ្ឍយន្តការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការ កម្មវិធី គម្រោងអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន
- រៀបចំរបាយការណ៍ស្តីពីសមិទ្ធផលការងារសាធារណការ និងដឹកជញ្ជូន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ជំពូកទី ៦

## អគ្គនាយកដ្ឋានបច្ចេកទេស

**មាត្រា ២១ .-**

អគ្គនាយកដ្ឋានបច្ចេកទេស មានភារកិច្ចដឹកនាំ គ្រប់គ្រង ត្រួតពិនិត្យ និងសម្របសម្រួលការរៀបចំបទប្បញ្ញត្តិ និងស្តង់ដារបច្ចេកទេស ផែនការមេអភិវឌ្ឍបណ្តាញផ្លូវថ្នល់ គម្រោងប្លង់សាងសង់ និទស្សន៍សំណង់ គុណភាពសម្ភារៈ និងវាយតម្លៃគុណភាពសំណង់ផ្លូវថ្នល់ ឬសំណង់ហេដ្ឋារចនាសម្ព័ន្ធសាធារណការ និងដឹកជញ្ជូន។

អគ្គនាយកដ្ឋានបច្ចេកទេស មាននាយកដ្ឋានចំណុះចំនួន៤ ដូចខាងក្រោម៖

១- នាយកដ្ឋានផ្លូវថ្នល់

២- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

៣- នាយកដ្ឋានបច្ចេកទេសសាធារណការ និងដឹកជញ្ជូន

៤- វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន។

**មាត្រា ២២ .-**

នាយកដ្ឋានផ្លូវថ្នល់ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវជាតិ ផ្លូវខេត្ត និងទ្រព្យសម្បត្តិសាធារណៈដែលពាក់ព័ន្ធនឹងវិស័យសាធារណការថ្នាក់ជាតិ
- តាមដាន ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ និងវាយតម្លៃលើការរៀបចំកម្មវិធីសាងសង់ ជួសជុល ថែទាំការដ្ឋានសាងសង់ផ្លូវ ថ្នល់ ស្ពាន និងកំពង់ចម្លងនៅតាមបណ្តាញផ្លូវជាតិ និងផ្លូវខេត្ត
- គ្រប់គ្រង ចុះបញ្ជី ចេញអាជ្ញាប័ណ្ណ លើការងារអាជីវកម្ម សាជីវកម្ម មន្ទីរពិសោធន៍ និងការវិនិយោគទាំងរដ្ឋ និងឯកជនលើវិស័យសាធារណការ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណភាពសំណង់ផ្លូវថ្នល់ ឬសំណង់ហេដ្ឋារចនាសម្ព័ន្ធសាធារណការ និងដឹកជញ្ជូនដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ២៣ .-**

នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធសាធារណការ ទ្រព្យសម្បត្តិសាធារណៈថ្នាក់ក្រោមជាតិដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួង
- គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃការងារសាងសង់ផ្លូវ-ស្ពាន អនុវត្តដោយអង្គភាពវិស្វកម្ម ៨៥



www.pheakdeylaw.com

- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអភិវឌ្ឍប្លង់មេ បណ្ដាញហេដ្ឋារចនាសម្ព័ន្ធសាធារណការ នៅតាមទីប្រជុំជននៃខេត្ត ក្រុង ស្រុក ខណ្ឌ និងរាជធានី
- គ្រប់គ្រងគម្រោងទីចំណតយានយន្ត សួនច្បារ និងរុក្ខកម្មក្នុងរាជធានី ខេត្ត
- រៀបចំបទដ្ឋានបច្ចេកទេសសម្រាប់គ្រប់គ្រងការងារហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិ និងវិស្វកម្ម
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ២៤ .-**

នាយកដ្ឋានបច្ចេកទេសសាធារណការ និងដឹកជញ្ជូន មានភារកិច្ចដូចតទៅ៖

- រៀបចំបទប្បញ្ញត្តិបច្ចេកទេស និងស្តង់ដារបច្ចេកទេសលើវិស័យសាធារណការ និងដឹកជញ្ជូន
- សិក្សាស្រាវជ្រាវ និងរៀបចំគម្រោងប្លង់សាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណការ
- សិក្សាស្រាវជ្រាវ និងរៀបចំនិទស្សន៍សំណង់ គុណភាពសម្ភារៈ និងបញ្ចូលបទពិសោធន៍ បច្ចេកវិទ្យាថ្មីទំនើបសម្រាប់អនុវត្តការងារវិស័យសាធារណការ និងដឹកជញ្ជូន
- គ្រប់គ្រងបណ្ណាល័យឯកសារបច្ចេកទេស ការងារនិទស្សន៍សំណង់ គុណភាពសម្ភារៈ និងបញ្ចូលបទពិសោធន៍ បច្ចេកវិទ្យាថ្មីទំនើបសម្រាប់អនុវត្តការងារវិស័យសាធារណការ
- សិក្សាលើកគម្រោងប្លង់ និងត្រួតពិនិត្យការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណការ
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ២៥ .-**

វិទ្យាស្ថានជាតិបណ្ដុះបណ្ដាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន មានភារកិច្ចដូចតទៅ៖

- រៀបចំបទប្បញ្ញត្តិបច្ចេកទេស និងស្តង់ដារបច្ចេកទេសលើវិស័យសាធារណការ និងដឹកជញ្ជូន
- រៀបចំគោលនយោបាយ ផែនការប្រតិបត្តិសម្រាប់ការពង្រឹង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ទាំងមន្ត្រីរាជការនៃក្រសួងសាធារណការ និងដឹកជញ្ជូន និងសិស្ស និស្សិត
- សិក្សាស្រាវជ្រាវរៀបចំផែនការមេ អភិវឌ្ឍបណ្ដាញផ្លូវថ្នល់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង/ឬចូលរួមសហការជាមួយប្រទេសម្ចាស់ជំនួយដៃគូអភិវឌ្ឍ ទីភ្នាក់ងារអន្តរជាតិ និងក្រុមហ៊ុននានា ដើម្បីធ្វើការសិក្សាលទ្ធភាពបឋម រាល់គម្រោងសាងសង់ផ្លូវថ្នល់ ឬគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- សិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មាននានាពាក់ព័ន្ធនឹងតម្រូវការបណ្ដុះបណ្ដាល ទីផ្សារការងារ ដើម្បីកំណត់អំពីកម្រិត និងតម្រូវការជំនាញបច្ចេកទេសសម្រាប់ការបណ្ដុះបណ្ដាល
- រៀបចំឱ្យមានបណ្ណាល័យរក្សាឯកសារបច្ចេកទេស បន្ទប់ពិសោធន៍សម្រាប់ការសិក្សាស្រាវជ្រាវ ការធ្វើពិសោធន៍វត្ថុធាតុដើម សំណង់ថ្មីៗ និងបច្ចេកវិទ្យាថ្មីៗសមស្របតាមល័ក្ខខ័ណ្ឌនៅកម្ពុជា
- សម្របសម្រួល និងដឹកនាំការចុះធ្វើកម្មសិក្សាជាក់ស្ដែង នៅតាមការដ្ឋានសាងសង់ សំណង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដើម្បីអភិវឌ្ឍសមត្ថភាពបច្ចេកទេសដល់មន្ត្រីរាជការ សិក្ខាកាម សិស្ស និងនិស្សិត
- សម្របសម្រួល តម្រង់ទិស និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ ទីភ្នាក់ងារអន្តរជាតិ និងវិស័យឯកជនព្រមទាំងអង្គភាព សហគ្រាសសាធារណៈចំណុះ ក្រសួងដើម្បី ពិនិត្យ សិក្សាស្រាវជ្រាវ និងផលិតមេរៀន កាលវិភាគ កម្មវិធីសិក្សា និងសម្ភារៈឧបទេស សម្រាប់ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសឱ្យស្របទៅនឹងស្ថានភាព និងតម្រូវការបណ្ដុះបណ្ដាល ក៏ដូចជាតម្រូវការទីផ្សារការងារទាំងពេលបច្ចុប្បន្ន និងទៅអនាគត ដោយ



www.pheakdeylaw.com

ធានាបាននូវគុណវុឌ្ឍិប្រសិទ្ធភាពស្របតាមគោលការណ៍ បទដ្ឋានគរុកោសល្យរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្របសម្រួល និងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ សម្រាប់ស្វែងរកការគាំទ្រជំនួយឧបត្ថម្ភទាំងផ្នែកបច្ចេកទេស ថវិកា សម្រាប់ការសិក្សាស្រាវជ្រាវការផលិតកម្មវិធីសិក្សា និងទស្សនកិច្ចសិក្សាទាំងក្នុង និងក្រៅប្រទេស

- ជំរុញកិច្ចសហប្រតិបត្តិការ ការសម្របសម្រួលទាំងផ្ទៃក្នុងក្រសួង បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ដើម្បីរួមចំណែកពង្រឹងសមត្ថភាពជំនាញ និងអភិវឌ្ឍធនធានមនុស្សឱ្យមានគុណវុឌ្ឍិឆ្លើយតបនឹងការវិវត្ត រីកចម្រើនវិស័យសាធារណការ និងដឹកជញ្ជូន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ជំពូកទី ៧
## អគ្គនាយកដ្ឋានសាធារណការ

### មាត្រា ២៦ .-

អគ្គនាយកដ្ឋានសាធារណការ មានភារកិច្ចដឹកនាំ គ្រប់គ្រង សម្របសម្រួល តម្រង់ទិស ណែនាំតាមដានត្រួតពិនិត្យការងារស្ថាបនា សាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណការ ទ្រព្យសម្បត្តិសាធារណៈ ដំណើរការវិនិយោគអាជីវកម្ម ដើម្បីអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន។

អគ្គនាយកដ្ឋានសាធារណការ មាននាយកដ្ឋានចំណុះចំនួន៤ ដូចខាងក្រោម៖

១- នាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគ
២- នាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់
៣- នាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវ
៤- នាយកដ្ឋានជួសជុល និងថែទាំផ្លូវថ្នល់។

នាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគ មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍផ្លូវល្បឿនលឿន ស្ពានធំៗ
- កសាងប្លង់មេ សិក្សាស្រាវជ្រាវគម្រោងប្លង់ ទាំងស្ថាបត្យកម្ម វិស្វកម្ម និងតម្លៃ
- រៀបចំផែនការសកម្មភាព គ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការងារអនុវត្តគម្រោងសាងសង់ផ្លូវល្បឿនលឿន និងស្ពានធំៗថ្មី
- អង្កេត ត្រួតពិនិត្យផ្លូវល្បឿនលឿនចាស់ និងស្ពានធំៗមានស្រាប់
- រៀបចំផែនការជួសជុល ថែទាំជាប្រចាំ
- កសាងច្បាប់ លិខិតបទដ្ឋានគតិយុត្តសម្រាប់អាជីវកម្ម និងវិនិយោគលើវិស័យផ្លូវល្បឿនលឿន និងស្ពានធំៗ
- រៀបចំឯកសារសម្រាប់លទ្ធកម្មសាធារណៈ ធ្វើការដេញថ្លៃ
- គ្រប់គ្រង តាមដាន វាយតម្លៃលើការវិនិយោគ
- អនុវត្តកិច្ចសន្យាក្នុងប្រតិបត្តិការអាជីវកម្ម ជួសជុល ថែទាំ និងចំណូលចំណាយ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ មានភារកិច្ចដូចតទៅ៖



www.pheakdeylaw.com

- គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធចម្រោះទឹកកខ្វក់
- រៀបចំបទប្បញ្ញត្តិ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍប្រព័ន្ធចម្រោះទឹកកខ្វក់
- លើកគម្រោងផែនការសម្រាប់ស្តារឡើងវិញ សាងសង់ ជួសជុល និងថែទាំប្រព័ន្ធចម្រោះទឹកកខ្វក់ ការតភ្ជាប់ប្រព័ន្ធចម្រោះទឹកកខ្វក់
- ពិនិត្យផ្តល់យោបល់លើបច្ចេកទេស ផែនការអភិវឌ្ឍប្រព័ន្ធចម្រោះទឹកកខ្វក់នៅក្នុងរាជធានីខេត្ត ទីប្រជុំជន ក្រុង ស្រុក និងខណ្ឌ
- សិក្សាស្រាវជ្រាវបច្ចេកទេស និងបច្ចេកវិជ្ជាថ្មីៗបម្រើឱ្យប្រព័ន្ធចម្រោះទឹកកខ្វក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ២៧ .-**

នាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវ មានភារកិច្ចដូចតទៅ៖

- សិក្សាលើកគម្រោង និងអនុវត្តការស្តារ និងស្ថាបនាផ្លូវ
- គ្រប់គ្រង និងត្រួតពិនិត្យបរិក្ខារ-គ្រឿងចក្រ នៅក្រោមអាណាព្យាបាល ព្រមទាំងបម្រើសេវាកម្មជួសជុលគ្រឿងចក្រគ្រប់ប្រភេទ
- ធ្វើការបណ្តុះបណ្តាលបញ្ជាគ្រឿងចក្រធុនធ្ងន់
- រៀបចំស្រាវជ្រាវ ផ្សព្វផ្សាយបទប្បញ្ញត្តិស្តីពីសុវត្ថិភាពការងារ និងកសាងបទដ្ឋានបច្ចេកទេសក្នុងការបញ្ជាប្រើប្រាស់ និងថែទាំគ្រឿងចក្រ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ២៨ .-**

នាយកដ្ឋានជួសជុល និងថែទាំផ្លូវថ្នល់ មានភារកិច្ចដូចតទៅ៖

- អន្តរាគមន៍ជាបន្ទាន់ការងារជួសជុលផ្លូវ ស្ពាន និងលូ ការងារសាងសង់ ជួសជុល និងថែទាំផ្លូវ ស្ពាន និងលូគ្រប់ប្រភេទ នៅតាមបណ្តាញផ្លូវថ្នល់ និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធសាធារណការផ្សេងៗទៀត
- ស្រាវជ្រាវ ដើម្បីអភិវឌ្ឍបច្ចេកទេសសាងសង់ ជួសជុល និងថែទាំស្ពាន ថ្នល់
- គ្រប់គ្រង និងថែទាំគ្រឿងចក្រ និងគ្រឿងបរិក្ខារផ្សេងៗរបស់អង្គភាពឲ្យបានល្អ
- ត្រួតពិនិត្យស្ថានភាពស្ពាន ថ្នល់ និងលូគ្រប់ប្រភេទ នៅតាមបណ្តោយផ្លូវជាតិ និងផ្លូវខេត្ត
- រៀបចំផែនការឆ្នាំ និងទំនាក់ទំនងរកជំនួយសម្រាប់ការងារថែទាំ ជួសជុល ស្ថាបនាស្ពានថ្នល់ និងលូ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ជំពូកទី ៨
## អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក

**មាត្រា ២៩ .-**

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក មានភារកិច្ចដឹកនាំ គ្រប់គ្រង សម្របសម្រួលការងារពាក់ព័ន្ធវិស័យដឹកជញ្ជូនផ្លូវគោក។

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក មាននាយកដ្ឋានចំណុះចំនួន៣ ដូចខាងក្រោម៖

១- នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក

២- នាយកដ្ឋានសុវត្ថិភាពចរាចរណ៍ផ្លូវគោក

៣- នាយកដ្ឋានដឹកជញ្ជូនសាធារណៈក្រុង។ ៚



www.pheakdeylaw.com

**មាត្រា ៣០ .-**

នាយកដ្ឋាន ដឹកជញ្ជូនផ្លូវគោក មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រងការដឹកជញ្ជូនតាមផ្លូវគោក ចរាចរណ៍ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោក ការដឹកជញ្ជូនឆ្លងកាត់ព្រំដែនតាមផ្លូវគោក
- គ្រប់គ្រងយានយន្តគ្រប់ប្រភេទ ដែលធ្វើចរាចរណ៍តាមផ្លូវថ្នល់ ដូចជា ការចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់ និងផ្លាក លេខយានយន្ត ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ការធ្វើអាជីវកម្មយានយន្ត
- គ្រប់គ្រង និងផ្តល់ប័ណ្ណបើកបរយានយន្តគ្រប់ប្រភេទ
- គ្រប់គ្រងការប្រកបអាជីវកម្មដឹកជញ្ជូនក្នុងប្រទេស សាលាបង្រៀនបើកបរយានយន្ត យានដ្ឋានជួសជុល និង យានដ្ឋានកែច្នៃ និងដំឡើងយានយន្ត និងហាងលក់យានយន្តគ្រប់ប្រភេទ
- គ្រប់គ្រងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ក្នុងក្របខ័ណ្ឌទ្វេភាគីឬពហុភាគី ដូចជាការអនុញ្ញាតឱ្យយានយន្ត ធ្វើ អាជីវកម្ម ដឹកជញ្ជូនឆ្លងដែន និងការអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនឆ្លងដែន
- ប្រមូល ចងក្រង វិភាគ គ្រប់គ្រងស្ថិតិ និងទិន្នន័យអំពីការដឹកជញ្ជូនក្នុងប្រទេស ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន
- សហការជាមួយវិទ្យាស្ថានជាតិសាធារណការ និងដឹកជញ្ជូន រៀបចំសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាល វិទ្យាសាស្ត្របច្ចេកទេស បច្ចេកវិទ្យាថ្មីទំនើបពាក់ព័ន្ធនឹងទស្សនទាន និងចក្ខុវិស័យក្នុងកិច្ចអភិវឌ្ឍន៍លើវិស័យដឹក ជញ្ជូនតាមផ្លូវគោក
- អនុវត្តកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិ ឬអន្តរជាតិ លើការងារដឹកជញ្ជូនតាមផ្លូវគោក
- ដឹកនាំ អនុវត្ត ត្រួតពិនិត្យ និងតាមដានការអនុវត្តន៍ផែនការ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមផ្លូវគោក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ៣១ .-**

នាយកដ្ឋានសុវត្ថិភាពចរាចរណ៍ផ្លូវគោក មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងប្រតិបត្តិការប្រព័ន្ធត្រួតពិនិត្យចរាចរណ៍តាមផ្លូវគោក រួមទាំងការ ប្រមូល ចងក្រង វិភាគ គ្រប់គ្រងស្ថិតិ ទិន្នន័យអំពីជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក
- កសាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រគ្រប់គ្រងសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរណ៍ផ្លូវគោក
- រៀបចំអប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលលើផ្នែកសុវត្ថិភាពចរាចរណ៍
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- រៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងធ្វើការ ផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋាន គតិយុត្តដែលទាក់ទងនឹងការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសណ្តាប់ធ្នាប់សុវត្ថិភាព ចរាចរផ្លូវគោក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ៣២ .-**

នាយកដ្ឋានដឹកជញ្ជូនសាធារណៈក្រុង មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូន សាធារណៈផ្សេងៗ ។ល។



www.pheakdeylaw.com

- ប្រមូល ចងក្រង វិភាគ គ្រប់គ្រងស្ថិតិ និងទិន្នន័យអំពីការដឹកជញ្ជូន
- គ្រប់គ្រងការដឹកជញ្ជូនសាធារណៈ
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីអភិវឌ្ឍន៍វិស័យដឹកជញ្ជូន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ជំពូកទី ៩
## អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ

**មាត្រា ៣៣ .-**

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ មានភារកិច្ចដឹកនាំ គ្រប់គ្រង សម្របសម្រួលការងារពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ។

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ មាននាយកដ្ឋានចំណុះចំនួន៤ ដូចខាងក្រោម៖

១- នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក
២- នាយកដ្ឋាននាវាចរណ៍សមុទ្រ
៣- នាយកដ្ឋានរដ្ឋបាលកំពង់ផែ
៤- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ។

**មាត្រា ៣៤ .-**

នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការ គោលនយោបាយ ច្បាប់ និងបទបញ្ញាសម្រាប់គ្រប់គ្រងការដឹកជញ្ជូនតាមផ្លូវទឹក ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក ការសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលការដឹកជញ្ជូនផ្លូវទឹក
- គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹកសម្រាប់នាវាចរណ៍ ដូចជា ការបំពាក់ និងការងារថែទាំសញ្ញាជំនួយនាវាចរណ៍នៅតាមផ្លូវទឹក ការដឹក បូម ស្តារ និងការថែទាំផ្លូវទឹកសម្រាប់នាវាចរណ៍ ការសាងសង់សំណង់ការពារច្រាំងបាក់ ការសិក្សាស្រាវជ្រាវផ្លូវទឹក ការប្រើប្រាស់ផ្លូវទឹកសម្រាប់នាវាចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹកផ្សេងៗទៀត
- អង្កេតលើករណីគ្រោះថ្នាក់នាវាចរណ៍ តាមផ្លូវទឹក
- ប្រមូល ចងក្រង គ្រប់គ្រងស្ថិតិ និងទិន្នន័យ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការដឹកជញ្ជូនតាមផ្លូវទឹក ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក ការងារបណ្តុះបណ្តាលនាវាចរណ៍ និងការងារផ្សេងៗទៀត
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ បណ្តាប្រទេស និងដៃគូអភិវឌ្ឍនានាដើម្បីអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវទឹក ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក
- សហការជាមួយវិទ្យាស្ថានជាតិសាធារណការ និងដឹកជញ្ជូន រៀបចំសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលវិទ្យាសាស្ត្របច្ចេកទេស បច្ចេកវិទ្យាថ្មីទំនើបពាក់ព័ន្ធនឹងទស្សនទាន និងចក្ខុវិស័យក្នុងកិច្ចអភិវឌ្ឍន៍លើវិស័យដឹកជញ្ជូនតាមផ្លូវទឹក
- ដឹកនាំ អនុវត្ត ត្រួតពិនិត្យ តាមដាន និងសម្របសម្រួលការអនុវត្តន៍ច្បាប់ និងបទបញ្ញាផ្សេងៗ ដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមផ្លូវទឹក ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ៣៥ .-**

នាយកដ្ឋាននាវាចរណ៍សមុទ្រ មានភារកិច្ចដូចតទៅ៖ ៤ន



www.pheakdeylaw.com

- រៀបចំផែនការ គោលនយោបាយ ច្បាប់ និងបទបញ្ញាសម្រាប់គ្រប់គ្រងការដឹកជញ្ជូនតាមផ្លូវសមុទ្រ ការសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលការដឹកជញ្ជូនផ្លូវសមុទ្រ
- ធានាសុវត្ថិភាព និងសន្តិសុខសម្រាប់នាវា ស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ
- គ្រប់គ្រងក្រុមចំណាត់ថ្នាក់នាវា ឬអង្គការសន្តិសុខទទួលស្គាល់ដើម្បីបំពេញការងារបច្ចេកទេស ដែលពាក់ព័ន្ធនឹងសុវត្ថិភាពសន្តិសុខ និងបរិស្ថានសម្រាប់នាវា ស្របតាមច្បាប់ជាតិ និងអន្តរជាតិ
- គ្រប់គ្រងនាវា និងនាវិក ដូចជាការចុះបញ្ជីនាវា ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា ការត្រួតពិនិត្យនាវាបរទេស នៅតាមកំពង់ផែ ការសាងសង់ និងជួសជុលនាវា យានដ្ឋាននាវា ការធ្វើអាជីវកម្មដឹកជញ្ជូនតាមនាវា ការអនុញ្ញាតឱ្យនាវាបរទេសចូលក្នុងព្រះរាជាណាចក្រកម្ពុជា ការប្រកបអាជីវកម្ម ដឹកជញ្ជូនតាមផ្លូវទឹក កណ្តៀរកិច្ច ការផ្តល់សៀវភៅនាវិក និងសេវាកម្មផ្សេងទៀតដែលពាក់ព័ន្ធ
- អង្កេតលើករណីគ្រោះថ្នាក់នាវាចរណ៍
- គ្រប់គ្រងក្រុមចំណាត់ថ្នាក់នាវា ឬអង្គការសន្តិសុខទទួលស្គាល់ដើម្បីបំពេញការងារបច្ចេកទេស ដែលពាក់ព័ន្ធនឹងសុវត្ថិភាពសន្តិសុខ បរិស្ថានសម្រាប់នាវា ស្របតាមច្បាប់ជាតិ និងអន្តរជាតិ
- ប្រមូល ចងក្រង គ្រប់គ្រងស្ថិតិ និងទិន្នន័យ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការដឹកជញ្ជូនតាមផ្លូវសមុទ្រ ការងារបណ្តុះបណ្តាលនាវាចរណ៍ និងការងារផ្សេងៗទៀត
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ បណ្តាប្រទេស និងដៃគូអភិវឌ្ឍនានា ដើម្បីអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវសមុទ្រ
- សហការជាមួយវិទ្យាស្ថានជាតិសាធារណការ និងដឹកជញ្ជូន រៀបចំសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលវិទ្យាសាស្ត្របច្ចេកទេស បច្ចេកវិទ្យាថ្មីទំនើបពាក់ព័ន្ធនឹងទស្សនទាន និងចក្ខុវិស័យក្នុងកិច្ចអភិវឌ្ឍន៍លើវិស័យដឹកជញ្ជូនតាមផ្លូវសមុទ្រ
- ដឹកនាំ អនុវត្ត ត្រួតពិនិត្យ តាមដាន និងសម្របសម្រួលការអនុវត្តន៍ច្បាប់ និងបទបញ្ញាផ្សេងៗ ដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមផ្លូវសមុទ្រ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ៣៦ .-**

នាយកដ្ឋានរដ្ឋបាលកំពង់ផែ មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការ គោលនយោបាយ ច្បាប់ និងបទបញ្ញាសម្រាប់គ្រប់គ្រងកំពង់ផែ ការសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលការគ្រប់គ្រងកំពង់ផែ
- ធានាសុវត្ថិភាព និងសន្តិសុខសម្រាប់កំពង់ផែ ស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ
- គ្រប់គ្រងកំពង់ផែ ដូចជា ការរៀបចំប្លង់ ការសាងសង់ ការធ្វើប្រតិបត្តិការកំពង់ផែ ការគ្រប់គ្រង និងចាត់ចែងចលនានាវានៅកំពង់ផែ សន្តិសុខកំពង់ផែ និងការងារពាក់ព័ន្ធផ្សេងៗទៀត
- គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹកសម្រាប់នាវាចរណ៍ ដូចជា ការបំពាក់ និងការងារថែទាំសញ្ញាជំនួយនាវាចរណ៍
- គ្រប់គ្រងក្រុមចំណាត់ថ្នាក់នាវា ឬអង្គការសន្តិសុខទទួលស្គាល់ ដើម្បីបំពេញការងារបច្ចេកទេស ដែលពាក់ព័ន្ធនឹងសុវត្ថិភាព សន្តិសុខ បរិស្ថានសម្រាប់កំពង់ផែ ស្របតាមច្បាប់ជាតិ និងអន្តរជាតិ
- ប្រមូល ចងក្រង គ្រប់គ្រងស្ថិតិ និងទិន្នន័យ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកំពង់ផែ
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ បណ្តាប្រទេស និងដៃគូអភិវឌ្ឍនានា ដើម្បីអភិវឌ្ឍកំពង់ផែ
- សហការជាមួយវិទ្យាស្ថានជាតិសាធារណការ និងដឹកជញ្ជូន រៀបចំសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលវិទ្យា៩៩



www.pheakdeylaw.com

សាស្ត្របច្ចេកទេស បច្ចេកវិទ្យាថ្មីទំនើបពាក់ព័ន្ធនឹងទស្សនទាន និងចក្ខុវិស័យក្នុងកិច្ចអភិវឌ្ឍន៍កំពង់ផែ

- តាមដាន ត្រួតពិនិត្យ រុករក និងសង្គ្រោះនាវា ត្រៀមទប់ទល់ និងឆ្លើយតបនឹងការកំពប់ប្រេងនៅតាមផ្លូវទឹកសមុទ្រ និងរួមចំណែកការពារបរិស្ថាន ដែលបង្កដោយការបំពុលពីនាវា
- ដឹកនាំ អនុវត្ត ត្រួតពិនិត្យ តាមដាន និងសម្របសម្រួលការអនុវត្តន៍ច្បាប់ និងបទបញ្ញាផ្សេងៗ ដែលពាក់ព័ន្ធនឹងកំពង់ផែ
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ៣៧ .-**

នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ មានភារកិច្ចដូចតទៅ៖

- សិក្សា និងធ្វើការងារទាំងឡាយដែលទាក់ទងជលមាគ៌ា នាវាចរណ៍តាមផ្លូវទឹក
- រៀបចំប្លង់ និងផែនទីទន្លេ ច្រកចង្អៀត និងប្រឡាយ
- កសាងផ្លាក និងពោងសញ្ញានាវាចរណ៍តាមផ្លូវទឹក
- រៀបចំវិធានការទាំងឡាយ ដែលបង្កលក្ខណៈទាំងអស់ ដែលបង្កលក្ខណៈរាំងស្ទះដល់នាវាចរណ៍ និងចរន្តផ្លូវទឹក
- ផ្សព្វផ្សាយជូនដំណឹងនានា ដល់អ្នកបើកបរ នូវឧបសគ្គដែលលេចឡើងថ្មី
- រៀបចំឲ្យមានគោលនយោបាយដឹកជញ្ជូនក្បូន ផ្ទះបណ្តែតទឹក ចតទៅតាមកន្លែងសមស្របត្រឹមត្រូវ
- សិក្សាស្រាវជ្រាវលើការងារ និងការពារច្រាំងបាក់
- លើកវិធានការ និងបូមស្តារទន្លេឲ្យមានជម្រៅទឹកល្អ ដើម្បីបម្រើការងារដឹកជញ្ជូន
- សាងសង់កំពង់ផែក្នុងស្រុក ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន
- គ្រប់គ្រងដីចំណីផ្លូវទឹក
- ពិនិត្យសំណើសុំទឹកពីទន្លេ និងបញ្ជូនទឹកមកទន្លេវិញ ដែលអាចមានផលប៉ះពាល់ដល់ជម្រៅទឹក
- កសាងពន្ធ និងចរាចរលើគោលនយោបាយដឹកជញ្ជូន ដែលប្រើប្រាស់មាគ៌ា នាវាចរណ៍
- កត់ត្រាកំពស់ទឹក តាមដងទន្លេទូទាំងប្រទេស សម្រាប់ការងារចរាចរណ៍ផ្លូវទឹក
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ជំពូកទី ១០

## អគ្គនាយកដ្ឋានភស្តុភារកម្ម

**មាត្រា ៣៨ .-**

អគ្គនាយកដ្ឋានភស្តុភារកម្ម មានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារពាក់ព័ន្ធនឹងវិស័យភស្តុភារកម្ម។

អគ្គនាយកដ្ឋានភស្តុភារកម្ម មាននាយកដ្ឋានចំណុះចំនួន៤ ដូចខាងក្រោម៖

១- នាយកដ្ឋានព័ត៌មានភស្តុភារកម្ម

២- នាយកដ្ឋានភស្តុភារកម្ម

៣- នាយកដ្ឋានសហប្រតិបត្តិការភស្តុភារកម្ម

៤- នាយកដ្ឋានអង្កេត និងបូកសរុប។

**មាត្រា ៣៩ .-**

នាយកដ្ឋានព័ត៌មានភស្តុភារកម្ម មានភារកិច្ចដូចតទៅ៖

- ប្រមូលផ្តុំទិន្នន័យ ភស្តុភារកម្ម លើទីផ្សារជាតិ និងអន្តរជាតិ



www.pheakdeylaw.com

- សិក្សាស្រាវជ្រាវ និងវិភាគលើទិន្នន័យភស្តុភាកម្ម
- ប្រមូលសរុប និងផ្សព្វផ្សាយទិន្នន័យភស្តុភាកម្ម
- ប្រើប្រាស់ទិន្នន័យភស្តុភាកម្មជាមូលដ្ឋានក្នុងការដាក់ចេញនូវគោលនយោបាយភស្តុភាកម្មថ្នាក់ជាតិ
- ស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗ ក្នុងគោលបំណងលើកកម្ពស់ពហុវិស័យដឹកជញ្ជូន ពហុគំរូក្នុងវិស័យដឹកជញ្ជូន និងភស្តុភាកម្ម
- ចងក្រង និងតម្កល់ឯកសារនានាដែលពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូន និងភស្តុភាកម្ម
- ចងក្រង និងផ្សព្វផ្សាយព័ត៌មាន បែបបទ នីតិវិធី តម្លៃ និងឯកសារនានា ដែលពាក់ព័ន្ធនឹងពហុវិស័យដឹកជញ្ជូន និងភស្តុភាកម្ម ក្នុងនិងក្រៅប្រទេស
- រៀបចំកម្មវិធីសិក្សា និងវគ្គបណ្តុះបណ្តាលជំនាញភស្តុភាកម្ម
- ជំរុញការអនុម័តកិច្ចព្រមព្រៀងនានា ដែលទាក់ទងនឹងជំនាញដឹកជញ្ជូន និងភស្តុភាកម្ម
- ធ្វើជាដៃគូជាមួយស្ថាប័នស្រាវជ្រាវ និងបណ្ឌិតសភា ខាងផ្នែកភស្តុភាកម្ម
- សម្របសម្រួលរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធក្នុងវិស័យឯកជន ក្នុងការតាមដាននិងគ្រប់គ្រងការអភិវឌ្ឍឧស្សាហកម្មភស្តុភាកម្ម
- ទំនាក់ទំនង និងសហការជិតស្និទ្ធជាមួយមជ្ឈមណ្ឌលព័ត៌មានដឹកជញ្ជូន និងភស្តុភាកម្មនានា ទាំងក្នុងនិងក្រៅប្រទេស ជាពិសេសជាមួយបណ្តាប្រទេសក្នុងសមាគមន៍អាស៊ាន សំដៅប្រមូលព័ត៌មាន និងចងជាសម្ព័ន្ធភាព
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ៤០ .-**

នាយកដ្ឋានភស្តុភាកម្ម មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយភស្តុភាកម្មថ្នាក់ជាតិ
- រៀបចំយុទ្ធសាស្ត្រតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធភស្តុភាកម្មផ្នែករឹង និងទន់ ក្នុងប្រព័ន្ធសេវាពហុដឹកជញ្ជូនបម្រើសេវាភស្តុភាកម្ម
- សម្រួលការតភ្ជាប់លំហូរនៃទំនិញគ្រប់ប្រភេទក្នុងប្រព័ន្ធភស្តុភាកម្ម
- រៀបចំលិខិតបទដ្ឋានគតិយុត្តនៃវិស័យភស្តុភាកម្ម
- រៀបចំផែនការភស្តុភាកម្ម
- រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យភស្តុភាកម្ម
- បំពេញភារកិច្ចជា លេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិភស្តុភាកម្ម និងគណៈកម្មការជាតិភស្តុភាកម្ម
- ជាស្ថាប័នបង្គោលនៅក្នុងក្រុមការងារវិស័យភស្តុភាកម្ម និងសេវាដឹកជញ្ជូន
- សម្របសម្រួលក្នុងការប្រមូលធាតុចូលនានា ខាងផ្នែកសេវាភស្តុភាកម្ម ដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងក្របខ័ណ្ឌក្នុងផ្នែកសេវាកម្មរបស់អាស៊ាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្ម-សេវាកម្មរបស់អាស៊ាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដទៃទៀត
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍប្រព័ន្ធភស្តុភាកម្ម និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធភស្តុភាកម្ម
- សហការ និងសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការរៀបចំគោលនយោបាយជាតិ យុទ្ធសាស្ត្រ ផែនការមេ ក្នុងគោលបំណងលើកកម្ពស់វិស័យដឹកជញ្ជូន និងភស្តុភាកម្ម នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ជូនក្រុមប្រឹក្សាជាតិភស្តុភាកម្ម ៤៩



www.pheakdeylaw.com

- សហការ និងសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីលើកកម្ពស់ការងារដឹកជញ្ជូនឆ្លងកាត់ ក្នុងតំបន់ និងក្នុងពិភពលោក
- អនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការនានា ក្នុងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការលើកគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធភស្តុភារកម្ម សម្រាប់ក្នុងស្រុក និងអន្តរជាតិ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការកៀងគរជំនួយហិរញ្ញវត្ថុ ដែលទាក់ទងនឹងពហុគំរូក្នុងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម ពីដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស និងព្រមទាំងដៃគូអភិវឌ្ឍន៍ថ្មីៗ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ៤១ .-**

នាយកដ្ឋានសហប្រតិបត្តិការភស្តុភារកម្ម មានភារកិច្ចដូចតទៅ៖

- សម្រួល និងសហការរវាងស្ថាប័នពាក់ព័ន្ធក្នុងប្រព័ន្ធភស្តុភារកម្ម
- សម្រួល និងផ្សាភ្ជាប់គោលការណ៍ច្បាប់ សារាចរ រវាងស្ថាប័នពាក់ព័ន្ធក្នុងប្រព័ន្ធភស្តុភារកម្ម
- សម្រួល និងផ្សាភ្ជាប់នីតិវិធីការងារ រវាងស្ថាប័នពាក់ព័ន្ធក្នុងប្រព័ន្ធភស្តុភារកម្ម
- រៀបចំវេទិកា រៀបចំផែនការភស្តុភារកម្ម
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការមេនានា ដែលទាក់ទងនឹងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម
- ពិនិត្យមើលឡើងវិញក្នុងពាក់កណ្តាលអណត្តិ និងចុងអណត្តិ នៃការអនុវត្តន៍គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការនានា ដែលទាក់ទងនឹងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់នូវសូចនាករសម្រាប់វាស់វែងការអនុវត្តន៍សកម្មភាពនានា ដែលត្រូវដាក់នៅក្នុងផែនការមេ នៃវិស័យដឹកជញ្ជូន និងភស្តុភារកម្ម
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៃការអនុវត្តន៍គម្រោងនានា ដែលទាក់ទងនឹងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម (វាយតម្លៃពាក់កណ្តាលអណត្តិ និងវាយតម្លៃបញ្ចប់គម្រោង)
- ផ្សព្វផ្សាយលទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃ នៃការអនុវត្តន៍គម្រោងនានា ដែលទាក់ទងនឹងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម
- សម្របសម្រួលក្នុងការអនុម័តច្បាប់ អនុសញ្ញា និងកិច្ចព្រមព្រៀងនានា ដែលទាក់ទងនឹងពហុគំរូក្នុងវិស័យដឹកជញ្ជូន និងភស្តុភារកម្មវិស័យ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**មាត្រា ៤២ .-**

នាយកដ្ឋានអង្កេត និងបូកសរុប មានភារកិច្ចដូចតទៅ៖

- អង្កេតព័ត៌មានគ្រប់ក្នុងប្រព័ន្ធភស្តុភារកម្ម
- បូកសរុបលទ្ធផលសម្រេចក្នុងប្រព័ន្ធភស្តុភារកម្ម
- បូកសរុបលទ្ធផលភស្តុភារកម្ម ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- រៀបចំតារាងស្ថិតិភស្តុភារកម្ម
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង



www.pheakdeylaw.com

- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

## ជំពូកទី ១១
## អគ្គាធិការដ្ឋាន

**មាត្រា ៤៣ .-**

អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន និងមានភារកិច្ចដូចតទៅ៖

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួង និងស្ថាប័នឯកជនជាដៃគូ
- ទទួល និងពិនិត្យដោះស្រាយរាល់វិវាទ និងពាក្យបណ្តឹងបុគ្គល ឬអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង និងស្ថាប័នឯកជនជាដៃគូ
- តាមដានការអនុវត្តន៍ច្បាប់ និងរាល់កិច្ចសន្យាទាំងឡាយដែលគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង និងស្ថាប័នឯកជន ជាដៃគូរបាន និងកំពុងអនុវត្ត
- ធ្វើរបាយការណ៍ពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចរួច និងពីមធ្យោបាយកែលម្អ ការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ
- ធ្វើអធិការកិច្ចសំណង់របស់ក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងករណីចាំបាច់
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

## ជំពូកទី ១២
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា ៤៤.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការចំណុះផ្ទាល់ប្រធានស្ថាប័នក្រសួងសាធារណការ និងដឹកជញ្ជូន ដោយទទួលបន្ទុកអនុវត្តភារកិច្ចស្របតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ដូចតទៅ៖

- ធ្វើសវនកម្មគ្រប់នាយកដ្ឋាន មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត សហគ្រាសសាធារណៈ ស្ថាប័នឯកជនពាក់ព័ន្ធអង្គភាពនៃគម្រោងដៃគូអភិវឌ្ឍន៍ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងលើភាពទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ បច្ចេកទេស ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងអនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត ដែលអង្គភាពមានភារកិច្ចត្រូវអនុវត្ត ដើម្បីបង្ការ និងកាត់បន្ថយហានិភ័យ បង្កើនប្រសិទ្ធភាព ប្រសិទ្ធផលការងារ
- រៀបចំ និងអនុវត្តគោលការណ៍ណែនាំ ផែនការ នីតិវិធី និងស្តង់ដារពាក់ព័ន្ធសវនកម្មផ្ទៃក្នុង
- វាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់គ្រប់នាយកដ្ឋាន មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត សហគ្រាសសាធារណៈ ស្ថាប័នឯកជនពាក់ព័ន្ធ អង្គភាពនៃគម្រោងដៃគូអភិវឌ្ឍន៍ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង លើការពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួង សំដៅពង្រឹងអភិបាលកិច្ចល្អ
- ធ្វើរបាយការណ៍ត្រង់ទៅប្រធានស្ថាប័ន ដោយធ្វើច្បាប់ចម្លងទៅអាជ្ញាធរសវនកម្មជាតិ និងសម្របសម្រួលការងារជាមួយសមត្ថកិច្ចត្រួតពិនិត្យនានា
- រៀបចំគម្រោងផែនការសកម្មភាពសវនកម្មផ្ទៃក្នុង ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ និងផែនការសកម្មភាពរយៈមុខតាមការចង្អុលណែនាំរបស់ប្រធានស្ថាប័ន ឬតាមសេចក្តីត្រូវការជាក់ស្តែង នៃគោលដៅផែនការយុទ្ធសាស្ត្ររបស់ក្រសួង និងរាជរដ្ឋាភិបាល
- ចុះសិក្សាស្រាវជ្រាវ ស៊ើបអង្កេត និងត្រួតពិនិត្យស្វែងយល់រាល់ព័ត៌មាន និងហេតុការណ៍អំពីភាពមិនប្រក្រតីលើ៥



www.pheakdeylaw.com

ការគ្រប់គ្រងផ្នែកពាក់ព័ន្ធខាងហិរញ្ញវត្ថុ និងថវិការបស់រដ្ឋ ថវិកាសាធារណៈ ឬអំណោយបានមកពីប្រភពផ្សេងៗ

- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

## ជំពូកទី ១៣
## នាយកដ្ឋានផ្លូវដែក

**មាត្រា ៤៥.-**

នាយកដ្ឋានផ្លូវដែក បំពេញមុខងារជាសេនាធិការចំណុះផ្ទាល់ប្រធានស្ថាប័នក្រសួងសាធារណការ និងដឹកជញ្ជូន ដោយទទួលបន្ទុក ដូចតទៅ៖

- រៀបចំ និងតាក់តែងគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធបណ្តាញគមនាគមន៍ផ្លូវដែកនៅកម្ពុជា តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ប្រកបដោយប្រសិទ្ធភាព និងមានភាពប្រកួតប្រជែងខ្ពស់
- លើកគម្រោងថវិកាប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកាបម្រើឱ្យរាល់ការចំណាយរបស់អគ្គនាយកដ្ឋានផ្លូវដែក និងចំណាយអនុវត្តគម្រោងសាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក
- រៀបចំធ្វើសម្រង់ទិន្នន័យហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក ដោយធ្វើការវិភាគ និងវាយតម្លៃ ដើម្បីធ្វើការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកឱ្យមានចីរភាព និងសមស្របតាមស្ថានភាពអភិវឌ្ឍន៍
- រៀបចំឯកសារបច្ចេកទេសប្រើប្រាស់ផ្លូវដែក និងសិល្បការ្យ ព្រមទាំងព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើហេដ្ឋារចនាសម្ព័ន្ធ និងការដឹកជញ្ជូនតាមផ្លូវដែក
- គ្រប់គ្រងទ្រព្យសម្បត្តិ ចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ ធ្វើបញ្ជីសារពើភណ្ឌ និងធ្វើកម្មវិធីចំណាយ និងបែងចែកសម្ភារៈបរិក្ខារបស់នាយកដ្ឋានផ្លូវដែក
- គ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក កម្មករ និងរៀបចំតួនាទី និងមុខតំណែងឯកទេសនៅក្នុងនាយកដ្ឋានផ្លូវដែក ដោយធ្វើទំនាក់ទំនងជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង
- សិក្សា និងវាយតម្លៃតម្រូវការបណ្តុះបណ្តាលមន្ត្រីរាជការ បុគ្គលិក កម្មករ និងលើកសំណើសុំធ្វើការបណ្តុះបណ្តាល ឬបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសជំនាញសម្រាប់បំពេញតម្រូវការចាំបាច់នៅក្នុងនាយកដ្ឋានផ្លូវដែក
- សហការជាមួយវិទ្យាស្ថានជាតិសាធារណការ និងដឹកជញ្ជូន រៀបចំសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលវិទ្យាសាស្ត្របច្ចេកទេស បច្ចេកវិទ្យាថ្មីទំនើបពាក់ព័ន្ធនឹងទស្សនទាន និងចក្ខុវិស័យក្នុងកិច្ចអភិវឌ្ឍន៍លើវិស័យផ្លូវដែក
- សិក្សាស្រាវជ្រាវ និងចូលរួមធ្វើការផ្សព្វផ្សាយបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងបច្ចេកទេសថ្មីៗដែលទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក និទស្សន៍សំណង់ គុណភាពសម្ភារៈ និងបច្ចេកទេសថ្មីសម្រាប់អនុវត្តការងារសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក
- សិក្សាស្រាវជ្រាវ លើកគម្រោង និងអនុវត្តការងារសាងសង់ ពង្រីក ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក និងសំណង់សិល្បការ្យផ្លូវដែក
- សិក្សាស្រាវជ្រាវ និងតាក់តែង ចងក្រងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងផ្លូវដែក និងចូលរួមប្រឹក្សា ឬផ្តល់យោបល់សម្រាប់ដោះស្រាយវិវាទនានាដែលពាក់ព័ន្ធនឹងវិស័យផ្លូវដែក
- សិក្សាស្រាវជ្រាវ និងតាក់តែងចងក្រងបទដ្ឋានបច្ចេកទេសសម្រាប់បម្រើឱ្យការគ្រប់គ្រង ការជួសជុល ថែទាំ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យផ្លូវដែក
- សិក្សា រៀបចំតាក់តែង ចងក្រងបទដ្ឋាន និងគោលការណ៍ណែនាំនានា សម្រាប់បម្រើឱ្យការត្រួតពិនិត្យ [illegible] សណ្តាប់ធ្នាប់ សន្តិសុខ ចរាចរណ៍ខ្សែរថភ្លើង និងប្រតិបត្តិការផ្លូវដែក ព្រមទាំងបទដ្ឋានពាក់ព័ន្ធ[illegible]ការ ៤៨



www.pheakdeylaw.com

ដឹកជញ្ជូនតាមផ្លូវដែក ទាំងការដឹកជញ្ជូនអ្នកដំណើរ និងទំនិញគ្រប់ប្រភេទ

- ចូលរួមសហការ និងសម្របសម្រួលការងារក្នុងវិស័យផ្លូវដែកក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ត្រីភាគី អនុតំបន់ តំបន់ សកលលោក និងអង្គការអន្តរជាតិនានា
- ចូលរួមសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គម ដោយសារគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- អនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

## ជំពូកទី ១៤

## នាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ

**មាត្រា ៤៦.-**

នាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈបំពេញមុខងារជាសេនាធិការឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន និងមានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យា និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាគេហទំព័រ អនុគេហទំព័រ និងសារអេឡិចត្រូនិចរបស់ក្រសួង
- រៀបចំប្រមូលផ្តុំទិន្នន័យ គ្រប់គ្រងទិន្នន័យ ធ្វើសុខដុមនីយកម្មប្រព័ន្ធ ឬកម្មវិធីរបស់អង្គភាពនានាក្រោមឱវាទក្រសួង និងតម្កល់ទុកជាឃ្លាំងទិន្នន័យនូវរាល់សំណុំឯកសាររបស់ក្រសួងផ្នែកទន់ ដើម្បីបម្រើរាល់ការសិក្សាស្រាវជ្រាវរបស់មន្ត្រីរាជការក្រោមឱវាទក្រសួង សិស្ស និងនិស្សិត
- ប្រមូលព័ត៌មានពាក់ព័ន្ធនឹងការងាររបស់ក្រសួង រួមទាំងការងារប្រចាំខែ និងការងារបន្ទាន់ រាយការណ៍ផ្ទាល់ជូនរដ្ឋមន្ត្រី ដើម្បីមានវិធានការដោះស្រាយ
- ស្រាវជ្រាវ និងវិភាគព័ត៌មានដែលផ្សព្វផ្សាយតាមគេហទំព័រ ឬកម្មវិធីប្រព័ន្ធបណ្តាញសង្គមរបស់ក្រសួង ព្រមទាំងកំណត់ហានិភ័យហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា ដែលអាចកើតមានឡើង ដើម្បីការពារ និងទប់ស្កាត់
- សហការជាមួយអង្គភាពក្រោមឱវាទក្រសួងទាំងអស់ ដើម្បីស្នើសុំ និងជ្រើសរើសឯកសារ និងរូបភាព សកម្មភាពផ្សេងៗ ផ្សព្វផ្សាយក្នុងគេហទំព័រ និងប្រព័ន្ធសង្គមរបស់ក្រសួង
- សិក្សា ស្រាវជ្រាវលើបច្ចេកវិទ្យាព័ត៌មានថ្មីៗ ព្រមទាំងនិន្នាការបច្ចេកវិទ្យាព័ត៌មាន និងលំហូរការងារ ដើម្បីលើកសំណើសុំការផ្លាស់ប្តូរថ្មីសម្រាប់បម្រើវិស័យសាធារណការ និងដឹកជញ្ជូន
- សិក្សាតម្រូវការធ្វើការទំនើបកម្ម និងស្វ័យប្រវត្តិកម្ម លើវិស័យព័ត៌មានវិទ្យា និងធ្វើការបណ្តុះបណ្តាលព័ត៌មានវិទ្យាដល់មន្ត្រីក្រោមឱវាទក្រសួង
- តាមដាន ត្រួតពិនិត្យ ថែទាំហេដ្ឋារចនាសម្ព័ន្ធបណ្តាញព័ត៌មានវិទ្យារបស់ក្រសួង ដោយធ្វើការទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ចូលរួមសហការលើការងារព័ត៌មានវិទ្យា និងការងារផ្សព្វផ្សាយក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរក្រសួង
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- អនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

## ជំពូកទី ១៥

## អង្គភាពលទ្ធកម្ម

**មាត្រា ៤៧ .-**

អង្គភាពលទ្ធកម្ម បំពេញមុខងារជាសេនាធិការស្ថិតក្រោមប្រធានស្ថាប័នផ្ទាល់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងមានភារកិច្ចដូចតទៅ៖ ៩៩



www.pheakdeylaw.com

- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការកែតម្រូវក្នុងករណីចាំបាច់
- រៀបចំឯកសារ និងនីតិវិធីពាក់ព័ន្ធនឹងកិច្ចការដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសារដេញថ្លៃ និងគោលការណ៍ណែនាំនានា ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តន៍កិច្ចសន្យា និងប្រគល់-ទទួលសំណង់ ទំនិញ សេវា និងរៀបចំសំណុំឯកសារចាំបាច់បញ្ជូនទៅអង្គភាពមានសមត្ថកិច្ច ដើម្បីរៀបចំធ្វើការទូទាត់
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តន៍កិច្ចការលទ្ធកម្មប្រចាំខែ ត្រីមាស ឆមាស ៩ខែ ឆ្នាំ និងសកម្មភាពផ្សេងៗរបស់អង្គភាពជូនប្រធានស្ថាប័ន
- អនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

## ជំពូកទី ១៦
## អង្គភាពថ្នាក់មូលដ្ឋាន

**មាត្រា ៤៨.-**

នៅគ្រប់រាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា មានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពការងារ លើវិស័យសាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្តនីមួយៗមានការិយាល័យអង្គភាពនានាចំណុះ និងមានការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក ខណ្ឌ ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពការងារពាក់ព័ន្ធនឹងវិស័យសាធារណការ និងដឹកជញ្ជូននៅកម្រិតមូលដ្ឋាន។

## ជំពូកទី ១៧
## សហគ្រាសសាធារណៈ

**មាត្រា ៤៩.-**

សហគ្រាសសាធារណៈ ជានីតិបុគ្គល មានភារកិច្ចទទួលបន្ទុកការងារទៅតាមជំនាញឯកទេសរបស់អង្គភាពនីមួយៗ ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៦៩៦/០៣ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ និងអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រម លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។

សហគ្រាសសាធារណៈ ទាំងនោះ រួមមាន៖

- កំពង់ផែស្វយ័តភ្នំពេញ
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ
- ភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)
- មន្ទីរពិសោធន៍សំណង់ និងសាធារណការ។

សហគ្រាសសាធារណៈខាងលើនេះ ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លក្ខន្តិកៈសហគ្រាសសាធារណៈ ត្រូវកំណត់តាមសំណើសុំពីក្រុមប្រឹក្សាភិបាលដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។៚



www.pheakdeylaw.com

## ជំពូកទី ១៨
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ៥០.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាដូចមានកំណត់ក្នុងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី ១៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៥១ .-**

ប្រកាសស្តីពីការបង្កើតឬការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គាធិការដ្ឋាន និងនាយកដ្ឋាន ចំណុះឱ្យអគ្គនាយកដ្ឋាន ឬនាយកដ្ឋាន ឬអង្គភាពក្រោមឱវាទក្រសួង និងអង្គភាពមូលដ្ឋាននៃក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបន្តអានុភាពអនុវត្តរហូតដល់មានប្រកាសថ្មីរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនជំនួស។

## ជំពូកទី ២០
## អវសានប្បញ្ញត្តិ

**មាត្រា ៥២.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យដូចខាងក្រោម៖

- អនុក្រឹត្យលេខ១៨អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- អនុក្រឹត្យលេខ១៣៩អនក្រ.បក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- អនុក្រឹត្យលេខ៥៦អនក្រ.បក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការបង្កើតនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- អនុក្រឹត្យលេខ២១៨អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតវិទ្យាស្ថាននាវាចរណ៍កម្ពុជា
- អនុក្រឹត្យលេខ១៦៣អនក្រ.បក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៩ ស្តីពីការបង្កើតនាយកដ្ឋានផ្លូវដែក ចំណុះក្រសួងសាធារណការ និងដឹកជញ្ជូន
- អនុក្រឹត្យលេខ១៧៥អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការបង្កើតនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិ និងវិស្វកម្ម ជំនួសនាយកដ្ឋានសំណង់ផ្លូវអាកាស
- អនុក្រឹត្យលេខ៦១ អនក្រ.បក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតមជ្ឈមណ្ឌលជួសជុល និងថែទាំផ្លូវថ្នល់នៃក្រសួងសាធារណការ និងដឹកជញ្ជូន
- អនុក្រឹត្យលេខ៣០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគនៃក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា ៥៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ ៚



www.pheakdeylaw.com

**មាត្រា ៥៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ  និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ ១០ ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## អង្គការលេខរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន






www.pheakdeylaw.com